# ច្បាប់

# ស្តីពី

# ការទប់ស្កាត់អំពើហិង្សា

# ក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលបំណងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គម នៅព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មានទិសដៅបង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្តជាធរមាន ។

## ជំពូកទី ២

## វិសាលភាពនៃការអនុវត្ត

**មាត្រា ២.-**

អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ :

១-ប្តី ឬ ប្រពន្ធ

២-កូនក្នុងបន្ទុក

៣-ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ ។

**មាត្រា ៣.-**

អំពើហិង្សាក្នុងគ្រួសារ ទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលា និង ប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុតដើម្បីការពារជនរងគ្រោះ ឬ ជនអាចនឹងរងគ្រោះ ។

អំពើហិង្សារួមមាន :

-ការប៉ះពាល់ដល់ជីវិត

-ការប៉ះពាល់ដល់បូរណភាពរូបកាយ

-ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ

-ការឈ្លានពានខាងផ្លូវភេទ ។

**មាត្រា ៤.–**

អំពើប៉ះពាល់ដល់ជីវិត រួមមាន :

-មនុស្សឃាតដោយគិតទុកជាមុន

-មនុស្សឃាតដោយចេតនា

-មនុស្សឃាតដោយអចេតនា បណ្តាលមកពីអំពើចេតនាផ្សេងទៀតនៃជនល្មើស

-មនុស្សឃាតដោយអចេតនា ។

**មាត្រា ៥.–**

អំពើប៉ះពាល់ដល់បូរណភាពរូបកាយ រួមមាន :

-ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬ ឥតអាវុធមានរបួស ឬ គ្មានរបួស

-ការធ្វើទារុណកម្ម ឬ ការធ្វើអំពើឃោរឃៅ ។

**មាត្រា ៦.–**

អំពើទារុណកម្ម ឬ អំពើឃោរឃៅ រួមមាន :

-ការធ្វើទុក្ខបុកម្នេញបង្កឱ្យមានការឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍ បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ

-ការធ្វើឱ្យប៉ះទង្គិចលើផ្លូវចិត្ត និងលើរូបកាយដែលប្រព្រឹត្តហួសពីសីលធម៌ និងច្បាប់កំណត់ ។

**មាត្រា ៧.–**

អំពើឈ្លានពានខាងផ្លូវភេទ រួមមាន :

-ការប្រើហិង្សាសេពសន្ថវៈ

-ការបៀតបៀនកេរ្តិ៍ខ្មាស

-ការធ្វើអាស្រូវភាស ។

**មាត្រា ៨.-**

ត្រូវទប់ស្កាត់ផងដែរ ចំពោះអំពើគំរាមកំហែងក្នុងគោលបំណងធ្វើឱ្យជនរងគ្រោះភ័យខ្លាច តក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិនៃជនដែលរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារតែមួយ ។

មិនរាប់បញ្ចូលថាជាការប្រើហិង្សា ឬ សកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មាន ឬ ធ្វើការដាស់តឿនក្រើនរំលឹក ឬ ចាត់វិធានការនានាសមស្របដើម្បីឱ្យសហព័ទ្ធ ឬ កូន ឬ អ្នកនៅក្នុងបន្ទុកដើរក្នុងផ្លូវល្អតាមលក្ខណៈរស់នៅថ្លៃថ្នូរ និងទំនៀមទម្លាប់និងប្រពៃណីល្អរបស់ជាតិ ប្រសិនបើការប្រៀនប្រដៅនិងការអប់រំនោះធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌និងស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## សមត្ថកិច្ច និងនីតិវិធី

**មាត្រា ៩.-**

អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ក្នុងករណីមានអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬ បម្រុងនឹងកើតឡើង ដើម្បីទប់ស្កាត់និងការពារជនរងគ្រោះ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

**មាត្រា ១០.-**

ក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ មន្ត្រីនៃក្រសួងកិច្ចការនារីបម្រើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់នេះ ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឱ្យជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ១១.-**

ក្នុងករណីអវត្តមាននៃមន្ត្រីដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌រួច ហើយនោះ មន្ត្រីសមត្ថកិច្ចដទៃទៀតរួមមាន មន្ត្រីនគរបាល ភ្នាក់ងារនគរបាល កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន ឃុំ សង្កាត់ មន្ត្រីរបស់ក្រសួងកិច្ចការនារី រួមទាំងមេភូមិដែលបានធ្វើអន្តរាគមន៍ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះត្រូវបានទទួលអំណាចពីច្បាប់នេះ ដើម្បីធ្វើកំណត់ហេតុជូនទៅតុលាការ ។ កំណត់ហេតុនេះ មានតម្លៃស្មើគ្នាដូចកំណត់ហេតុដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ដែរ ។

**មាត្រា ១២.-**

ក្នុងការអនុវត្តភារកិច្ច អាជ្ញាធរមានសមត្ថកិច្ចដូចបានចែងក្នុងមាត្រា ៩ មាត្រា ១០ និងមាត្រា ១១ ខាងលើនេះ ត្រូវគោរពតាមនីតិវិធីដែលបានកំណត់ក្នុងបញ្ញត្តិនៃច្បាប់នេះ និងនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៤
## វិធានការទប់ស្កាត់ និងការការពារជនរងគ្រោះ

**មាត្រា ១៣.-**

ដើម្បីទប់ស្កាត់អំពើហិង្សាដែលកំពុងតែកើត ឬ ជឿជាក់ថានឹងកើតឡើង អាជ្ញាធរមានសមត្ថកិច្ច ត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ដោយ :

-ឃាត់ទុកអាវុធ ឬ វត្ថុជាក់ស្តែងដែលជនមុខសញ្ញាបាន ឬ អាចប្រើប្រាស់

-បង្វែរយកចេញជនមុខសញ្ញាពីកន្លែងកើតហេតុ ឬ បង្វែរជនរងគ្រោះ

បើមានការស្នើសុំពីជនរងគ្រោះ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំ ប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

-ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្នដែលអាចធានាសុវត្ថិភាព និងផ្តល់នូវជំនួយសុខាភិបាលជាបន្ទាន់

-ពន្យល់ អប់រំ និងសម្រុះសម្រួលគូភាគីទាំងសងខាងឱ្យបញ្ឈប់អំពើហិង្សា និងណែនាំជនរងគ្រោះអំពីសិទ្ធិរបស់ខ្លួនសម្រាប់ទប់ស្កាត់អំពើហិង្សាដែលមានចែងនៅក្នុងមាត្រា ២០ និងមាត្រា ២៦ នៃច្បាប់នេះ ។

ជនមុខសញ្ញាក្នុងច្បាប់នេះ គឺសំដៅដល់អ្នកដែលបានប្រព្រឹត្ត កំពុងប្រព្រឹត្តនិងត្រៀមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ។

**មាត្រា ១៤.-**

ដើម្បីការពារសន្តិសុខជនរងគ្រោះ អាជ្ញាធរមានសមត្ថកិច្ចអាចចេញសេចក្តីសម្រេចរដ្ឋបាលស្របតាមមាត្រា ៤៣ មាត្រា ៤៨ និងមាត្រា ៤៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងចាត់វិធានការបណ្តោះអាសន្នស្របច្បាប់ដែលមានជាអាទិ៍ :

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង

-ហាមបំផ្លាញទ្រព្យសម្បត្តិ ឬ ណែនាំកុំឱ្យចាត់ចែងលក់ទ្រព្យសម្បត្តិរួម ឬ របស់ជនរងគ្រោះ ឬ របស់ញាតិសាលោហិតរបស់ជនរងគ្រោះ

-ហាមជនមុខសញ្ញាចូលទៅជិត ឬ ចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច

-ចាត់វិធានការស្របច្បាប់ផ្សេងទៀត ដែលចាំបាច់សម្រាប់ការពារសុវត្ថិភាពដល់ជនរងគ្រោះ និងសមាជិកក្នុងគ្រួសារ ឬជនដែលពាក់ព័ន្ធ ។

មាត្រា ១៥.-

បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើតឡើងហើយ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិចូលទៅក្នុងទីកន្លែងកើតហេតុ ទោះជាពុំមានដីកាតុលាការអនុញ្ញាតឱ្យចូលក៏ដោយ ក្នុងករណីទាំងឡាយណាដែលមន្ត្រី និងភ្នាក់ងារមានសមត្ថកិច្ច យល់ដោយសមហេតុផលថាមានអំពើហិង្សាក្នុងគ្រួសារបានកើតឡើងក្នុងអំឡុងពេល ៤៨ម៉ោងកន្លងផុត ឬនឹងអាចកើតឡើងក្នុងអំឡុងពេល ២៤ម៉ោងខាងមុខ ។

ក្នុងអំឡុងពេលចូលធ្វើអន្តរាគមន៍ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍នោះ រួចរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច ។

មាត្រា ១៦.-

ទន្ទឹមនឹងការធ្វើអន្តរាគមន៍របស់អាជ្ញាធរមានសមត្ថកិច្ច ជនរងគ្រោះអាចធ្វើបណ្តឹងទៅតុលាការខេត្ត ក្រុង ដើម្បីសុំឱ្យចេញដីកាការពារ ។

ចៅក្រមដែលទទួលបន្ទុកការ ត្រូវចេញដីកាការពារដោយមានវត្តមាន ឬ ពុំចាំបាច់មានវត្តមានជនមុខសញ្ញា ។

មាត្រា ១៧.-

ក្នុងការចូលរួមអនុវត្តនីតិវិធីព្រហ្មទណ្ឌជាធរមាន អាជ្ញាធរមានសមត្ថកិច្ចពុំអាចធ្វើអន្តរាគមន៍ដើម្បីផ្សះផ្សា ឬ សម្រុះសម្រួលបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈជាបទឧក្រិដ្ឋ ឬ មជ្ឈិមធ្ងន់ធ្ងរបានទេ ។

មាត្រា ១៨.-

អាជ្ញាធរមានសមត្ថកិច្ច អាចឃាត់ខ្លួនជនមុខសញ្ញាដែលកំពុងប្រព្រឹត្តអំពើហិង្សាជាក់ស្តែង ឬ ជនមុខសញ្ញាណាដែលកំពុងតែរំលោភលើដីកាការពាររបស់តុលាការដូចមានចែងក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ដោយពុំចាំបាច់មានដីកាតុលាការ ។ ប៉ុន្តែក្រៅពីករណីទាំងពីរនេះ ការឃាត់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ចដែលពុំមានដីកាពីតុលាការ ត្រូវហាមឃាត់ ។

ក្នុងករណីអនុវត្តតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ ខាងលើនេះ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុច្បាស់លាស់ កសាងសំណុំរឿង និងបញ្ជូនជនមុខសញ្ញាដែលត្រូវឃាត់ខ្លួនទៅតុលាការជាបន្ទាន់ ក្នុងអំឡុងពេលអតិបរិមាដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីចាត់វិធានការបន្ថែមឱ្យស្របច្បាប់ ។

**មាត្រា ១៩.–**

អំពើហិង្សាក្នុងគ្រួសារណាដែលមានចរិតជាបទល្មើសព្រហ្មទណ្ឌមានលក្ខណៈជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមធ្ងន់ធ្ងរ ត្រូវតែជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ទោះអំពើហិង្សានេះបានកន្លងផុតហើយក៏ដោយ ។

បណ្តឹងអាជ្ញា ត្រូវធ្វើឡើងតាមបែបបទដែលមានចែងក្នុងច្បាប់នេះ និងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៥
## សិទ្ធិអំណាចតុលាការ

**មាត្រា ២០.–**

ដីកាការពារមានអនុភាពបង្គាប់បញ្ជាលើជនមុខសញ្ញា លើអាជ្ញាធរមានសមត្ថកិច្ច និងលើជនដែលពាក់ព័ន្ធនឹងរឿងក្តីនេះ ។ ដីកាការពារនេះ ជាវិធានការផ្នែករដ្ឋប្បវេណី ។

ដីកាការពារមានកម្មវត្ថុចង្អុលបង្ហាញអំពីស្ថានភាព សកម្មភាព ឬអាកប្បកិរិយាទាំងអស់ជាការបង្គាប់ឱ្យធ្វើក្តី ឬ បញ្ជាហាមឃាត់ធ្វើក្តី ដែលទាក់ទិនទៅនឹងតម្រូវការការពារជនរងគ្រោះ ឬ បុគ្គលណាដែលទទួលការគំរាមកំហែងពីអំពើហិង្សាក្នុងគ្រួសារ ។

ដីកាការពារមាន :

១-ឥទ្ធិពលសម្រាប់មួយរយៈ

២-ឥទ្ធិពលបណ្តោះអាសន្នស្របតាមបញ្ញត្តិនៃមាត្រា ២៣ នៃច្បាប់នេះ ។

ចៅក្រមមានសមត្ថកិច្ចមានសិទ្ធិចេញដីកាការពារជាថ្មី ស្របតាមស្ថានភាពជាក់ស្តែង ឬ បទបញ្ជាណាមួយក្នុងលក្ខណៈសមស្រប ។

**មាត្រា ២១.-**

មានតែតុលាការខេត្ត ក្រុងទេ ដែលមានសមត្ថកិច្ចចេញដីកាការពារជាប្រយោជន៍ដល់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារលើគ្រប់ករណីទាំងអស់ ទោះជាអំពើហិង្សាក្នុងគ្រួសារនោះកើតឡើងផ្ទួនគ្នាជាផ្នែកស៊ីវិលក្តី ជាផ្នែករដ្ឋបាលក្តី ឬ ជាផ្នែកព្រហ្មទណ្ឌក្តី ។

**មាត្រា ២២.-**

ពាក្យបណ្តឹងសុំដីកាការពារពីតុលាការអាចធ្វើឡើងដោយ :

១-ជនរងគ្រោះ ឬ តំណាងជនរងគ្រោះ ឬ អាជ្ញាធរមានសមត្ថកិច្ចនៃលំនៅឋានជនរងគ្រោះ ឬ មន្ត្រី ភ្នាក់ងារដែលបំពេញការងារនៅកន្លែងកើតហេតុ ។

២-ជនណាម្នាក់ដែលបានដឹងពីឧបទ្ទវហេតុនៃអំពើហិង្សាក្នុងគ្រួសារ ប្រសិនបើជនរងគ្រោះជាកុមារ ជាជនវិកលចរិត ឬ ជាជនដែលតុលាការយល់ថាគ្មានលទ្ធភាពធ្វើពាក្យបណ្តឹងដោយខ្លួនឯងបាន ។

**មាត្រា ២៣.-**

ដីកាការពារមានពីរដំណាក់កាល :

១-ដំណាក់កាលទី ១ ហៅថាដីកាការពារបណ្តោះអាសន្នដែលមានរយៈពេល ២(ពីរ)ខែ ចេញក្នុងពេលដែលមានអាសន្នពីអំពើហិង្សាក្នុងគ្រួសារភ្លាមៗ ។

២-ដំណាក់កាលទី ២ ហៅថាដីកាការពារមានរយៈពេល ៦(ប្រាំមួយ)ខែ ចេញក្នុងពេលដែលតុលាការកំពុងស៊ើបអង្កេតមិនទាន់ជំនុំជម្រះ ឬ មុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៤.-**

តុលាការអាចចេញដីកាការពារបណ្តោះអាសន្ន នៅពេលទទួលបណ្តឹងការពារ

ដោយមិនចាំបាច់សាកសួរជនមុខសញ្ញា បើសិនវិធានការបណ្តោះអាសន្ននោះមានភាពចាំបាច់សម្រាប់រក្សាការពារសុវត្ថិភាពនិងសុខុមាលភាពរបស់ជនរងគ្រោះ ឬសម្រាប់ជាការរក្សាទុកជាបណ្តោះអាសន្ននូវទ្រព្យសម្បត្តិជនរងគ្រោះមុនមានសាលក្រមស្ថាពរ ។

**មាត្រា ២៥.-**

ក្នុងការចេញដីកាការពារ តុលាការមានសិទ្ធិកំណត់បញ្ហាលើសកម្មភាពជនមុខសញ្ញា ដើម្បីការពារជនរងគ្រោះដូចតទៅ :

-ហាមប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារដោយខ្លួនឯងផ្ទាល់ ឬ ដោយអ្នកផ្សេង

-ហាមចូលទៅជិត ឬ ចូលទៅក្នុងទីលំនៅរួម កន្លែងស្នាក់នៅ ឬ កន្លែងធ្វើការរបស់ជនរងគ្រោះ បើគ្មានការអនុញ្ញាតពីជនរងគ្រោះនិងអាជ្ញាធរមានសមត្ថកិច្ច ។

-ហាមជនមុខសញ្ញាទាក់ទងជាមួយជនរងគ្រោះតាមផ្លូវណាមួយ

-ហាមបំផ្លាញទ្រព្យ ឬ ចាត់ចែងលក់ទ្រព្យរបស់ជនរងគ្រោះឬញាតិសាលោហិតរបស់ជនរងគ្រោះ

-បំបែកជនមុខសញ្ញាពីលំនៅឋានរួម ឬ បំបែកជនរងគ្រោះ បើមានការស្នើសុំ ។ ក្នុងករណីពិសេស ជនរងគ្រោះអាចបង្វែរចេញបានដោយគ្មានការស្នើសុំប្រសិនបើមានហេតុផលចាំបាច់ត្រូវធ្វើ ។

បើយល់ថាជាការចាំបាច់សម្រាប់ការពារ ឬ រៀបចំសុវត្ថិភាព សុខភាព និងសុខុមាលភាពជនរងគ្រោះ តុលាការអាចបង្គាប់ដោយចាត់វិធានការបន្ថែមទៀតដូចតទៅ :

-បញ្ជាឱ្យភ្នាក់ងារនគរបាល ឬ កងរាជអាវុធហត្ថណាម្នាក់ការពារបេតិកភណ្ឌផ្ទាល់ខ្លួនរបស់ជនរងគ្រោះ

-សម្រេចអំពីការថែរក្សាកូន និងអំពីសិទ្ធិទៅសួរសុខទុក្ខកូន ដោយគិតយ៉ាងខ្ពស់បំផុតពីសិទ្ធិ និងផលប្រយោជន៍នៃកុមារនោះ

-បញ្ឈប់កាតព្វកិច្ចហិរញ្ញវត្ថុនៃជនរងគ្រោះចំពោះជនមុខសញ្ញា

-កំហិតឱ្យជនមុខសញ្ញាផ្តល់ជំនួយហិរញ្ញវត្ថុឱ្យជនរងគ្រោះដោយផ្អែកតាមលទ្ធភាពធនធាននៃជនមុខសញ្ញា ។

**មាត្រា ២៦.-**

ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្ត ឬ ផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាល ឬ បទលហុ ការផ្សះផ្សា ឬ សម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង ។ សមាជិកគ្រួសារអាចជ្រើសរើសវិធីណាមួយដោយស្នើសុំឪពុកម្តាយ សាច់ញាតិ ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យ មេភូមិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើជាអ្នកអាជ្ញាកណ្តាលដោះស្រាយបញ្ហា ដើម្បីថែរក្សាបាននូវភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៧.-**

អនុលោមលើខ្លឹមសារនៃមាត្រា ២៥ ខាងលើ តុលាការត្រូវព្យាយាមធ្វើការផ្សះផ្សាភាគីមានវិបត្តិអំពើហិង្សា ក្នុងលក្ខខណ្ឌឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់សមាជិកនៃគ្រួសារនោះ ។ ក្នុងការផ្សះផ្សាសម្រុះសម្រួលគ្នា តុលាការត្រូវចៀសវាងធ្វើសម្ពាធលើគូភាគីដែលមិនព្រមស្រុះស្រួលគ្នា ឬបង្ខិតបង្ខំភាគីណាមួយឱ្យចូលផ្សះផ្សា ឬ បង្ខិតបង្ខំឱ្យចុះកិច្ចព្រមព្រៀងដោយគ្មានការព្រមព្រៀងពីភាគីទាំងពីរឡើយ ។

**មាត្រា ២៨.-**

ក្នុងករណីអំពើហិង្សាពាក់ព័ន្ធដល់កុមារ អាជ្ញាធរមានសមត្ថកិច្ចដែលមានតួនាទីទទួលបន្ទុកបម្រើប្រយោជន៍កុមារនិងការពារសុខុមាលភាពកុមារ ធ្វើការតាមដានបញ្ហានេះ ។ ក្នុងករណីធ្ងន់ធ្ងរ អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងទៅតុលាការ ។

អ្នកទទួលខុសត្រូវណាម្នាក់ដែលតុលាការបានបង្គាប់រួមទាំងព្រះរាជអាជ្ញាផងត្រូវទទួលបន្ទុកតាមដានអំពីស្ថានភាពនៃកុមារ និងធ្វើសេចក្តីរាយការណ៍អំពីស្ថានភាពនេះជូនទៅតុលាការ ។

តុលាការអាចផ្តល់អាណត្តិដល់ស្ថាប័នមានសមត្ថកិច្ច ដើម្បីរកជំនួយនិងការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារព្រមទាំងការពារសុវត្ថិភាពនិងសុខុមាលភាពជនរងគ្រោះ ពេលតុលាការកំពុងបំពេញនីតិវិធី ។

**មាត្រា ២៩.-**

លើកលែងតែករណីបន្ទាន់ដូចមានចែងក្នុងមាត្រា ២៣ តុលាការត្រូវជូនដំណឹងទៅជនមុខសញ្ញាអំពីការស្នើសុំដីកាការពារមិនឱ្យលើសពី ៥(ប្រាំ)ថ្ងៃ មុននឹងយកបញ្ហានេះមកពិនិត្យ ។ បើជនមុខសញ្ញានេះមិនបង្ហាញខ្លួននៅមុខតុលាការ ដើម្បីបញ្ជាក់អំពីហេតុផល តុលាការអាចពិនិត្យបញ្ហាដោយពុំមានវត្តមានជនមុខសញ្ញា ឬ បើជាការចាំបាច់ អាចចាត់វិធានការតាមនីតិវិធីជាធរមាន ចំពោះជនមុខសញ្ញាដែលមិនអើពើនឹងសេចក្តីសម្រេចរបស់តុលាការ ។

ក្នុងករណីអវត្តមាន ឬ ការមិនអើពើរបស់ជនមុខសញ្ញាអំពីសេចក្តីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវស្នើតុលាការចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣០.-**

បើមានសំណើពីភាគីណាមួយ តុលាការអាចកែប្រែ លុបចេញ ឬ បន្ថែមទម្ងន់នៅក្នុងដីកាការពារក្រោយពីបានជូនដំណឹងទៅភាគីម្ខាងទៀត ៥(ប្រាំ)ថ្ងៃ មុននឹងសម្រេច ។

គូភាគីអាចធ្វើការតវ៉ាឱ្យតុលាការពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរ ២(ពីរ)ខែ ចាប់ពីថ្ងៃចេញដីកាការពារ ។

**មាត្រា ៣១.-**

ជនរងគ្រោះ និងជនមុខសញ្ញាមានសិទ្ធិទទួលអ្នកការពារតាមផ្លូវច្បាប់ ឬមានសិទ្ធិជ្រើសរើសអ្នកតំណាងដែលខ្លួនទុកចិត្ត នៅគ្រប់ដំណាក់កាលនៃនីតិវិធី ។

មាត្រា ៣២.-

ក្រោយពីបានចេញដីកាការពាររួចហើយ ព្រះរាជអាជ្ញា ឬ មន្ត្រីមានសមត្ថកិច្ចដែលច្បាប់ប្រគល់ឱ្យត្រូវចាត់គ្រប់វិធានការ ដើម្បីអនុវត្តដីកាការពារតាមនីតិវិធីកំណត់។

## ជំពូកទី ៦
## ការអប់រំ ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាល

មាត្រា ៣៣.-

រដ្ឋ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទូទាំងប្រទេសបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះ ជាពិសេសអំពីការទទួលខុសត្រូវក្នុងគ្រួសារ ការគោរពសិទ្ធិគ្នាទៅវិញទៅមកដើម្បីលើកស្ទួយតម្លៃគ្រួសារខ្មែរ សីលធម៌ សុជីវធម៌ ការរស់នៅ ការថែរក្សា និងការអប់រំគ្រួសារ របៀបដោះស្រាយទំនាស់ដោយអហិង្សា និងសន្តិវិធី ព្រមទាំងណែនាំឱ្យយល់ពីវិធានការទាំងឡាយក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

រដ្ឋជម្រុញភាគីដែលមានវិបត្តិអំពើហិង្សាក្នុងគ្រួសារឱ្យចូលរួមក្នុងវគ្គពិគ្រោះបញ្ហា ដើម្បីរៀនសូត្រស្វែងយល់អំពីវិធីសាស្ត្រនានា ក្នុងការដោះស្រាយទំនាស់ និងអប់រំដោយមិនប្រើប្រាស់អំពើហិង្សា ។

មាត្រា ៣៤.-

ក្រសួង ស្ថាប័នទាំងឡាយរបស់រដ្ឋត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន អង្គការនានា និងផ្នែកឯកជន ដើម្បីជម្រុញកម្មវិធីផ្សព្វផ្សាយនិងអប់រំប្រជាពលរដ្ឋអំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

មន្ត្រីពាក់ព័ន្ធទាំងឡាយ និងភ្នាក់ងារអង្គការនានាត្រូវបានទទួលការបណ្តុះបណ្តាលអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ និងវិធានការទាំងឡាយដែលមានចែងនៅក្នុងច្បាប់នេះ ដើម្បីឱ្យយល់ពីមូលហេតុចម្បងនានាដែលបង្កឱ្យមានការកើតឡើងនូវអំពើហិង្សាក្នុងគ្រួសារ និងបទល្មើសទាំងឡាយដែលពាក់ព័ន្ធវិស័យនេះ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៦.-**

ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើពីជនរងគ្រោះជានីតិជនដោយបទល្មើសនោះជាបទមជ្ឈិមស្រាល ឬ បទលហុ ។ ក្នុងករណីដែលមានអំពើហិង្សាក្នុងគ្រួសារកើតឡើងជាថ្មីម្តងទៀតដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើការចោទប្រកាន់ជនមុខសញ្ញារូបនោះតាមនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានការស្នើសុំពីជនរងគ្រោះម្តងទៀតក៏ដោយ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៧.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០០៥

នរ/រករ.១០០៥.២៤៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ហត្ថលេខា**

**អ៊ឹង កន្ថាផាវី**

លេខ ៤៤៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ីម ការ៉ា**